# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ៤៧៦/៧-៧-២០០៥

សាលដីកា

លេខៈ ១២០(៤)/២៧-១២-២០០៧

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខៈ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជា សាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី២៧-១២-២០០៧ ដែលមានសមាសភាពដូចតទៅ៖

### សមាសភាពក្រុមប្រឹក្សា

| | | |
|---|---|---|
| លោក | អ៊ុំ សារិទ្ធ | ជាប្រធាន |
| លោក | សំរិទ្ធិ សុផល | ចៅក្រមប្រឹក្សា |
| លោក | ប៉ាក់ ច័ន្ទសំបូរ | ចៅក្រមប្រឹក្សា |

### តំណាងមហាអយ្យការ

លោក ដេត ឆេមរ៉ា

### ក្រឡាបញ្ជីសវនាការ

លោក លី ទូច

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខៈ៤៧៦ ចុះថ្ងៃទី៧-៧-២០០៥ រវាង៖

-ជនជាប់ចោទឈ្មោះ[redacted]សំអុល ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ កើតនៅសង្កាត់គីឡូម៉ែត្រ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅសព្វ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ[redacted](រ) នៅលីវ ទោសពីមុនគ្មាន ។

ចាប់ខ្លួនថ្ងៃទី០៦.១២.២០០៤ ឃុំខ្លួនថ្ងៃទី១៤.១២.២០០៤ ។ បច្ចុប្បន្នឃុំខ្លួននៅពន្ធនាគារម៣ ។

មេធាវីការពារឈ្មោះ [redacted]វិនា

ត្រូវចោទពីបទៈប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦-១២-២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ស៊ីថាន ហៅ ផ្លក ភេទស្រី អាយុ៣៨ឆ្នាំ ទីលំនៅសព្វថ្ងៃផ្ទះ[redacted]សង្កាត់គីឡូម៉ែត្រ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] សយ (ស) ម្តាយឈ្មោះ [redacted](រ) ប្តីឈ្មោះ[redacted]មានកូន០១នាក់ ។

១០៧

## ឯរឿងហេតុមានដូចតទៅ

តាមរបាយការណ៍សំយោគរបស់អធិការដ្ឋាននគរបាលខណ្ឌឬស្សីកែវ បានរាយការណ៍ថា នៅថ្ងៃកើតហេតុជនល្មើសបានទៅសុំផ្ទះជនរងគ្រោះដេក ដល់ម៉ោង២២និង០០នាទី ជនល្មើសបានលបចូលតាមបង្អួចទៅក្នុងបន្ទប់ជនរងគ្រោះដែលដេកម្នាក់ឯង ហើយធ្វើសកម្មភាពសង្កត់ជនរងគ្រោះពីលើជនរងគ្រោះរើបំរះហើយស្រែកឱ្យអ្នកជិតខាងជួយ ជនល្មើសក៏គេចខ្លួនរត់បាត់ ។ ដល់ថ្ងៃទី១១.១២.២០០៤ វេលាម៉ោង១៦និង០០នាទី ក្រុមគ្រួសារជនរងគ្រោះបានចាប់ខ្លួនជនល្មើសមកប្រគល់ឱ្យសមត្ថកិច្ច ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ៤៩(គ) ចុះថ្ងៃទី២២-៤-២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] **សំអុល** ភេទប្រុស អាយុ២១ឆ្នាំ ដាក់ពន្ធនាគារកំណត់១០ឆ្នាំ(ដប់ឆ្នាំ) គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី១៤.១២.២០០៤ ពីបទៈប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៦-១២-២០០៤ តាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-បង្គាប់ឱ្យឈ្មោះ [redacted] **សំអុល** សងប្រាក់ជម្ងឺចិត្តចំនួន១០០ដុល្លា(មួយរយ)ដុល្លាអាមេរិក ទៅឱ្យឈ្មោះ [redacted] **ស៊ីថាន** ដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយសំណូមពរជម្ងឺចិត្តលើសពីនេះ ត្រូវបដិសេធចោល ។

ករណីរឹងទទឹងមិនព្រមសងត្រូវដាក់គុកបង្ខំលើរូបកាយឈ្មោះ[redacted]**សំអុល** និងរឹបអូសទ្រព្យសម្បត្តិផ្សេងៗរបស់ឈ្មោះ [redacted] **សំអុល** លក់ឡាយឡុងដើម្បីធានាសំណង ដោយអនុវត្តតាមនីតិវិធីដែលមានចែងក្នុងច្បាប់ស្តីពីការដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣-សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ បើកផ្លូវឧទ្ធរណ៍ក្នុងរយៈពេលពីរខែ គិតចាប់តាំងពីថ្ងៃនេះតទៅ ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី១៦-១០-២០០៧ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញសេចក្តីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាសង្ខេបរឿង

-ជនជាប់ចោទឈ្មោះ[redacted] **សំអុល** (អវត្តមាន)

-មេធាវីលោក [redacted] **វិនា** (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]**ស៊ីថាន ហៅ ធួក** (វត្តមាន)

-តំណាងមហាអយ្យការសន្និដ្ឋានថាៈ សូមតម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ៤៩(គ) ចុះថ្ងៃទី២២-៤-២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

-មេធាវីលោក [redacted] **វិនា** សន្និដ្ឋានថាៈ ដោយសារកូនក្តីខ្លួននៅក្នុងពន្ធនាគារ សូមក្រុមប្រឹក្សាពិចារណាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន ។

១០៨

-ក្រោយពីបានអានរបាយការណ៍

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍

## យល់ឃើញថា ៖

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥.៦.២០០៥ របស់ឈ្មោះ [redacted] ចេង ជាម្តាយជនជាប់ចោទ ធ្វើឡើងខុសទម្រង់ច្បាប់ យោងតាមបញ្ញត្តិមាត្រា១៦២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍មិនអាចទទួលជំនុំជម្រះបានឡើយ ។

២-លិខិតលេខ:៧៥៩ គ.ម.០៧ ចុះថ្ងៃទី៣០.១១.២០០៧ របស់គណៈមេធាវី ចាត់មេធាវី [redacted] វិនា ការពារជនជាប់ចោទ [redacted] សំអុល មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-មិនទទួលជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៥.៦.២០០៥ របស់ឈ្មោះ [redacted] ចេង ដោយខុសទម្រង់ច្បាប់ ។

២-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ និង ដើមបណ្តឹង កំបាំងមុខជនជាប់ចោទ ។

បើកផ្លូវប្តឹងតវ៉ា តាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី១៦ ខែ១០ ឆ្នាំ ២០១៤

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]

១០៩